# សុន្ទរកថា

## លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៃសារមន្ទីរជម្មជាតិ

## សកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ

ខេត្តព្រះវិហារ ថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨

- *សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ!*
- *សូមគោរព **ឯកឧត្តម ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *សូមគោរព សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី!*
- *សូមគោរពអង្គពិធីទាំងមូល!*

ជាបឋម តាងនាមឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរជាតិព្រះវិហារ បណ្តាអង្គភាពយោធា នគរបាល ប្រជាពលរដ្ឋ និងអង្គពិធីទាំងមូល នាងខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ចំពោះវត្តមានរបស់ **ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់កិត្តិយសអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ **សារមន្ទីរជម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ** នៅក្នុងថ្ងៃនេះ។

ជាមួយគ្នានេះ នាងខ្ញុំក៏សូមសម្តែងនូវសេចក្តីរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះ សម្តេច ឯកឧត្តម លោកជំទាវ មេបញ្ជាការ មេបញ្ជាការរង នាយទាហាន ពលទាហាន នាយនគរបាល ពលនគរបាល ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋទាំងអស់ ដែលបានអញ្ជើញចូលរួមយ៉ាងច្រើនកុះករ ញ៉ាំងអោយពិធីនេះ មានភាពអធិកអធមយ៉ាងក្រៃលែង។

ឆ្នាំ២០១៨នេះ ជាខួបអនុស្សាវរីយ៍លើកទី១០ នៃការចុះបញ្ជីប្រាសាទព្រះវិហារ ដែលជាស្នាដៃឯកនៃស្ថាបត្យកម្មខ្មែរ នៅក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។ ទាំងនេះ គឺជាលទ្ធផលនៃការខិតខំប្រឹងប្រែងយ៉ាងស្វិតស្វាញនិងប៉ិនប្រសប់របស់ សម្តេចវិបុលបញ្ញា **សុខ អាន** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមការងារថ្នាក់ជាតិ ជានិមិត្តរូបនៃស្មារតីសាមគ្គីជាតិដ៏រឹងមាំសម្រាប់ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈ ក្រោមការដឹកនាំដ៏វាងវៃរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ យើងគ្រប់គ្នាជាជនជាតិខ្មែរ ពិតជាមានមោទនភាពនូវទេពកោសល្យអច្ឆរិយៈ និងគោរពដឹងគុណរកទីបំផុតគ្មាន ចំពោះបុព្វបុរស ដែលបានបូជាជីវិត បង្ហូរញើស និងឈាម ផ្តល់ឱ្យកូនចៅជំនាន់ក្រោយនូវ

មរតកដែលមានតម្លៃមហាសាលមិនអាចកាត់ថ្លៃបាន និងជាប្រភពមិនចេះរីងស្ងួតនៃការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ ហើយដែលកូនខ្មែរគ្រប់ៗរូប និងជាពិសេសយុវជនជំនាន់ក្រោយ មានភារកិច្ចនិងកាតព្វកិច្ចក្នុងការថែរក្សាការពារ ដោយគ្រប់តម្លៃទាំងអស់ នូវរតនវត្ថុដែលមានតម្លៃជាសកលនេះ សម្រាប់ជាតិយើង សម្រាប់ពិភពលោកទាំងមូល និងសម្រាប់មនុស្សជាតិ អោយបានគង់វង្ស និងយូរអង្វែងតរៀងទៅ។ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** តែងតែប្រកាន់ខ្ជាប់នូវគោលការណ៍ស្តារ កសាង និងអភិវឌ្ឍប្រទេសទៅតាមចក្ខុវិស័យ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពដ៏ច្បាស់លាស់ និងប្រទាក់ក្រឡាគ្នា សម្រាប់ខេត្តព្រះវិហារនិយាយជារួម និងតំបន់ប្រាសាទព្រះវិហារនិយាយដោយឡែក ដោយបានកំណត់ទិសដៅយ៉ាងច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយទាក់ទងនឹងការការពារបូរណភាពដែនដី ការអភិរក្សនិងការអភិវឌ្ឍដែលជាមូលដ្ឋានគ្រឹះសំខាន់ៗដូចខាងក្រោម៖

១. ការពារឲ្យបានដាច់ខាតនូវឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា និងបន្តដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងឲ្យបានសម្រេច តាមរយៈការចរចារដោយសន្តិវិធី។

២. កសាងបន្ទាត់ព្រំដែនមួយជាមួយប្រទេសជិតខាង ជាព្រំដែនសន្តិភាព ស្ថេរភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍។ ជាសក្ខីភាពជាក់ស្តែង បង្ហាញឲ្យឃើញតាមរយៈការកសាងហេដ្ឋារចនសម្ព័ន្ធរូបវន្ត ដូចជាការកសាងផ្លូវបំបែកពីខេត្តកំពង់ធំមកដល់ប្រាសាទព្រះវិហារ ពីឃុំស្រយ៉ង់មកភ្ជាប់ផ្លូវលេខ៦២ និងពីខេត្តសៀមរាបមកកាន់ភូមិស្រអែមឆ្លងតាមស្រុកអន្លង់វែង ដែលមិនត្រឹមតែបានកាត់បន្ថយរយៈពេលធ្វើដំណើរប៉ុណ្ណោះទេ ប៉ុន្តែកំពុងផ្តល់នូវផលប្រយោជន៍ទាំងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដ៏ធំធេងដល់ប្រជាជន។

៣. ការកសាងភូមិដ្ឋានប្រជាជន និងគ្រួសារយុទ្ធជន ដើម្បីលើកកម្ពស់ជីវភាព កាត់បន្ថយភាពក្រីក្រគឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធការពារជាតិដ៏យូរអង្វែងរបស់រាជរដ្ឋាភិបាល ដូចជាគម្រោងជាច្រើននៅទិសប្រាសាទព្រះវិហារ បាននឹងកំពុងអនុវត្តយ៉ាងសកម្មស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយក្រុមការងារពិសេសថ្នាក់ជាតិ សហការជាមួយសាលាខេត្តព្រះវិហារ អាជ្ញាធរជាតិព្រះវិហារ និងបណ្តាអង្គភាពពាក់ព័ន្ធនៅក្នុងតំបន់ គឺជាសកម្មភាពអភិវឌ្ឍដែលយើងពុំធ្លាប់មានពីមុនមក។ ជាក់ស្តែង គម្រោងកសាងភូមិធម្មជាតិសម្តេចតេជោ គ្របដណ្តប់នៅលើផ្ទៃដីចំនួន៤៥០០ហិចតា ដែលមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើនដូចជា៖ ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ វត្តអារាម អាងស្តុកទឹក សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ។ល។ រួមទាំងការរៀបចំដោយជោគជ័យនូវតំបន់អភិរក្សប្រាសាទព្រះវិហារ គម្រោងអភិរក្ស និងស្តារហេដ្ឋារចនាសម្ព័ន្ធប្រាសាទមួយចំនួនទៀត តំបន់ដីសម្បទានសង្គមកិច្ចភូមិធម្មជាតិ និងដីអភិវឌ្ឍកសិកម្មយោធិន ដែលរហូតមកដល់បច្ចុប្បន្ននេះបានចំណាយថវិកាជាតិអស់ប្រមាណ៥៣ពាន់លានរៀល។

បច្ចុប្បន្ននេះ ក្រុមការងារពិសេសថ្នាក់ជាតិ កំពុងបន្តអនុវត្តបញ្ចប់គម្រោងរៀបចំខឿនការពារជាតិ និងប្រជាជនក្នុងតំបន់ប្រាសាទព្រះវិហារ ដែលដឹកនាំដោយទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធនានា និងអាជ្ញាធរដែនដី នឹងដោយមានការចូលរួមអនុវត្តដោយ ឯកឧត្តម **សួស យ៉ារ៉ា** ឯកឧត្តម **ជុច ភឿន** ឯកឧត្តម **អ៊ុន ចាន់ដា** ឯកឧត្តម **គឹម សេតារា** រួមជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសនៃអាជ្ញាធរជាតិព្រះវិហារទាំងអស់ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធពីនាយឧត្តមសេនីយ៍ **គន់ គឹម** នាយឧត្តមសេនីយ៍ **ជា តារា** នាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** នាយឧត្តមសេនីយ៍ **ខេង សុមេធ** និងឧត្តមសេនីយ៍ឯក **ស្រី ឌឹក**។

*ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីមេត្រី!*

ក្រៅពីផ្តោតលើកិច្ចការការពារជាតិ និងលើកកម្ពស់ជីវភាពប្រជាជននៅតាមបណ្តោយព្រំដែន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** បានផ្តួចផ្តើមកសាង **សារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ** នៅលើផ្ទៃដី ១៧៧ហិចតា កាលពីឆ្នាំ២០០៩ ដោយបានចំណាយថវិកាសរុបចំនួន៧៥៣,៤២៧ដុល្លា (ប្រាំពីររយហាសិបបីពាន់ បួនរយម្ភៃប្រាំពីរដុល្លាគត់) ដែលក្នុងនោះរួមមាន៖

- **សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ថវិកាចំនួន១៥០ ០០០ដុល្លា
- **ក្រុមហ៊ុន AEON** ថវិកាចំនួន១០០ ០០០ដុល្លា
- **នាយឧត្តមសេនីយ៍កិត្តិបណ្ឌិត ហ៊ីង ប៊ុនហៀង និងលោកជំទាវ** ថវិកាចំនួន៥០ ០០០ដុល្លា
- **ឯកឧត្តម សួស យ៉ារ៉ា និងលោកជំទាវ** ថវិកាចំនួន២៦៩ ៤២៧ដុល្លា
- **ថវិកាជាតិសម្រាប់ការរៀបចំតាំងពិពណ៌** ចំនួន១៨៤,០០០ដុល្លា
- **ជាមួយគ្នានេះដែរ អង្គការយូណេស្កូបានផ្តល់នូវកិច្ចសហការនៃជំនួយបច្ចេកទេសមួយផ្នែកធំ ក្នុងការរៀបចំ ការដាក់តាំងសមុច្ច័យផ្សេងៗក្នុងសារមន្ទីរនេះផងដែរ។**

បច្ចុប្បន្ននេះ សារមន្ទីរបានបញ្ចប់ការសាងសង់ និងការរៀបចំដាក់តាំងពិព័រណ៍ជំហានទី១ទាំងស្រុង លើផ្ទៃដីទំហំប្រមាណ១០ហិចតា ដោយកងវិស្វកម្មក្រុមការងារពិសេសថ្នាក់ជាតិ សហការជាមួយអាជ្ញាធរជាតិព្រះវិហារ អង្គការយូណេស្កូនៅកម្ពុជា អ្នកជំនាញជាតិ និងអន្តរជាតិ ដែលបានឆ្លុះបញ្ចាំងអំពីសាមគ្គីភាពផ្ទៃក្នុងរវាងអ្នកជំនាញការជាតិ និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានា។ សារមន្ទីរនេះ មានអគារសំខាន់ៗ ចំនួន៦គឺ៖ (១) អគារបដិសណ្ឋារកិច្ច និងការិយាល័យ (២) អគារពិព័រណ៍អចិន្ត្រៃយ៍ ចំនួន០២អគារ ដែលមានបែងចែកជាសាលពិព័រណ៍សិល្បៈបុរាណវិទ្យា សាលពិព័រណ៍ផ្នែកប្រវត្តិសាស្ត្រ សាលពិព័រណ៍ផ្នែកប្រពៃណី និងទំនៀមទំលាប់របស់ជនជាតិដើមភាគតិចកួយ និងសាលពិព័រណ៍ផ្នែកជីវិតសត្វ និងរុក្ខជាតិ (៣) សាលសោតទស្សន៍ចំនួន០១អគារ សម្រាប់ចាក់បង្ហាញវីដេអូខ្នាតខ្លីឲ្យភ្ញៀវទេសចរស្វែងយល់អំពីប្រាសាទព្រះវិហារ និងទំនៀមទំលាប់ ប្រពៃណី របស់ជនជាតិដើមភាគតិចកួយ (៤)អគារពិព័រណ៍មិនអចិន្ត្រៃយ៍ ចំនួន០១អគារ សម្រាប់ដាក់តាំងវត្ថុសិល្បៈ រយៈពេលខ្លី(៣ខែ ទៅ៦ខែ) បច្ចុប្បន្នកំពុងបង្ហាញអំពីពិព័រណ៍រូបថតក្រោមប្រធានបទ *"ស្នាមញញឹមនៃបេតិកភណ្ឌ"* ដែលជាស្នាដៃរបស់អ្នកថតរូបជនជាតិជប៉ុន (៥) អគាររោងជាង និងឃ្លាំងចំនួន០១ អគារ សម្រាប់ជួសជុល និងរក្សាទុកវត្ថុបុរាណដែលប្រមូលបាន និង(៦)ស្តូបបារមីលោកតាឪ ជាទីសក្ការបូជាមួយសម្រាប់ឧទ្ទិសដល់មេទ័ពខ្លាំងពូកែម្នាក់ឈ្មោះលោកតាឪ។

**សារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ** មានតួនាទីយ៉ាងសំខាន់ក្នុងការអភិរក្សវត្ថុបុរាណ វត្ថុសិល្បៈ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ ជំនឿ សាសនា ភាសារបស់ជនជាតិភាគដើមភាគតិចតិចកួយ រួមទាំងប្រភេទសត្វ និងរុក្ខជាតិនៅក្នុងតំបន់ព្រះវិហារ និងតំបន់ផ្សេងៗទៀត។ លើសពីនេះទៀត សារមន្ទីរគឺជាឃ្លាំងនៃចំណេះដឹង ជាកញ្ចក់ឆ្លុះបញ្ចាំងអំពីអតីតកាលរបស់ជាតិសាសន៍ខ្មែរ ហើយក៏ជាកន្លែងអប់រំ ផ្សព្វផ្សាយដល់សិស្សានុសិស្ស និស្សិត ប្រជាជន មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបញ្ជ្រាបចំណេះដឹងទូទៅ

ទាក់ទងនឹងវប្បធម៌ អរិយធម៌ ប្រវត្តិសាស្ត្រ តម្លៃបេតិកភណ្ឌ និងបរិស្ថាន ក្នុងគោលដៅបណ្តុះស្មារតីស្រឡាញ់ ការពារ អភិរក្ស និងផ្សព្វផ្សាយបន្តដល់កូនចៅជំនាន់ក្រោយ។

***ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់***

***ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីមេត្រី!***

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ នាងខ្ញុំសូមអនុញ្ញាតជម្រាបជូន *ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី* ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់អំពីទស្សនៈវិស័យ **សារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ** នៅថ្ងៃអនាគតមានគោលដៅចម្បងចំនួនបីគឺ៖ (១) ជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ ភាសា សិល្បៈ ជំនឿ សាសនា និងការរស់នៅប្រចាំថ្ងៃរបស់បណ្តាជនជាតិដើមភាគតិចទាំងអស់នៅក្នុងប្រទេសសំដៅប្រែក្លាយជាសារមន្ទីរជាតិពន្ធុវិទ្យាតែមួយគត់សម្រាប់ប្រទេសកម្ពុជា (២) ជាមជ្ឈមណ្ឌល អភិរក្សប្រភេទសត្វ និងរុក្ខជាតិ ព្រមទាំងប្រភេទឱសថបុរាណសម្រាប់បណ្តាប្រទេសតាមដងទន្លេមេគង្គ និង(៣) ជាមជ្ឈមណ្ឌលប្រមូលផ្តុំនូវវប្បធម៌ និងទេសចរណ៍សម្រាប់ជម្រុញខ្សែក្រវាត់កិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម។ ដើម្បីសម្រេចបាននូវទស្សនៈវិស័យនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រួមជាមួយអាជ្ញាធរជាតិព្រះវិហារ នឹងខិតខំប្រឹងប្រែងស្វែងរកថវិកាពីប្រភព ផ្សេងៗបន្ថែមទៀត ហើយយើងក៏សូមស្វាគមន៍ការចូលរួមចំណែកពីសប្បុរសជនជាតិ និងអន្តរជាតិ ព្រមទាំង បណ្តាប្រទេសជាមិត្តក្នុងក្របខណ្ឌ អាយស៊ីស៊ី ព្រះវិហារ និងស្ថាប័នជាតិ និងអន្តរជាតិពាក់ព័ន្ធទាំងអស់។

ជាថ្មីម្តងទៀត ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ក៏ដូចជាអង្គពិធីទាំងមូល និងជាប្រជាជនខ្មែរទូទាំងប្រទេស នាងខ្ញុំសូមគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលមិនត្រឹមតែបានដឹកនាំជួយសង្គ្រោះប្រជាជនកម្ពុជា ពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ឡើយ ក៏ប៉ុន្តែ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានការពារសម្បត្តិវប្បធម៌ ប្រាសាទបុរាណ និងទឹកដីនៅតាមបន្ទាត់ព្រំដែន មិនឲ្យបាត់បង់សូម្បីមួយមីល្លីម៉ែត្រ។ លើសពីនេះទៅទៀត **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានខិតខំលើកតម្កើងកេរតំណែលមរតកវប្បធម៌របស់កម្ពុជា រហូតទទួលបានកេរ្តិ៍ឈ្មោះល្បីល្បាញគ្រប់ទីកន្លែង និងបានក្លាយជាសម្បត្តិបេតិកភណ្ឌពិភពលោក ដូចជាប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ និងប្រាសាទសំបូរព្រៃគុក ហើយនឹងបន្តស្នើចុះបញ្ជីប្រាសាទនានាបន្តបន្ទាប់ទៀត។ លទ្ធផល និងស្នាដៃដ៏ធំធេង និងមានអត្ថន័យជ្រាលជ្រៅនេះ គឺសុទ្ធតែកើតចេញពីការប្រឹងប្រែង លះបង់អស់កម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញា និងកើតចេញពីសេចក្តីស្រឡាញ់ ខ្វល់ខ្វាយ និងយកចិត្តទុកដាក់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ចំពោះវិស័យវប្បធម៌ ចំពោះប្រជាជនគ្រប់ៗរូប និងចំពោះព្រះរាជាណាចក្រកម្ពុជាទាំងមូល។

ជាទីបញ្ចប់ ក្នុងនាមគណៈកម្មការអន្តរក្រសួង ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរជាតិព្រះវិហារ បណ្តាអង្គភាពយោធា នគរបាល ប្រជាពលរដ្ឋ និងអង្គពិធីទាំងមូល ដែលបានអញ្ជើញចូលរួមអបអរសាទរពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៃ **សារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន** នាពេលនេះ នាងខ្ញុំសូមបួងសួងដល់ ទេវតាឆ្នាំថ្មី ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ដែលនឹងឈានចូលមកដល់នាពេលដ៏ខ្លីខាងមុខ សូមព្រះអង្គតាមបីបាច់ថែរក្សា **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** សូមបានទទួលនូវភាពជោគជ័យ សិរីមង្គល និងវិបុលសុខ

គ្រប់ប្រការជានិច្ចនិរន្តរ៍ និងសូមគោរពជូនពរ សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយនគរបាល លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋទាំងអស់ និងអង្គពិធីទាំងមូល សូមប្រកបដោយព្រះពុទ្ធពរទាំង៤ប្រការ កុំបីឃ្លៀងឃ្លាតឡើយ។

*ជាកិច្ចបន្ត នាងខ្ញុំសូមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់គោរពអញ្ជើញ* **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** *មេត្តាអញ្ជើញថ្លែងសុន្ទរកថានិងផ្តល់នូវអនុសាសន៍គន្លឹះនានា ជូនដល់អង្គពិធីទាំងមូល ដោយសេចក្តីអនុគ្រោះ ។ សូមគោរពអញ្ជើញ !*

សូមអរគុណ